# សន្និសីទ និងពិព័រណ៍ទឹកកម្ពុជា លើកទី៤

## The 4th Cambodian Water Conference & Exhibition

# គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត

ថ្ងៃទី២៩ និងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

រៀបចំដោយ លោក តាំង សុចិត្រា
អគ្គនាយករងនៃអគ្គនាយកដ្ឋានទឹកស្អាត

# មាតិការឿង

I. គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

បានទទួលការឯកភាពពីគណៈរដ្ឋមន្រ្តី ៖

–ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

–ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣)

II. គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត–ក្រុង និងទីប្រជុំជន

# I. គោលនយោបាយផ្គត់ផ្គង់ទឹកស្អាត ខេត្ត-ក្រុង និងទីប្រជុំជន

គោលនយោបាយផ្គត់ផ្គង់ទឹកស្អាតចែកចេញជា៦ជំពូកគឺ៖

១- វិធីសាស្រ្តនៃការផ្គត់ផ្គង់

២- ការចូលរួមពីផ្នែកឯកជន

៣- ការកំណត់ថ្លៃទឹក

៤- ការការពារជនក្រីក្រ និងការឧបត្ថម្ភធន

៥- ស្វ័យភាពនៃអង្គភាពសេវាសាធារណៈ

៦- បញ្ញត្តិករទឹកស្អាត

# ១. វិធីសាស្ត្រនៃការផ្គត់ផ្គង់ទឹកស្អាត

វិធីសាស្ត្រ២ ដើម្បីដោះស្រាយក្នុងការផ្គត់ផ្គង់ទឹកស្អាតៈ

១- វិធីសាស្ត្រដោះស្រាយតាមការផ្គត់ផ្គង់ៈ មានទ្រង់ទ្រាយធំ ទុនវិនិយោគផ្តោតលើតំរូវការទឹករបស់ប្រជាពលរដ្ឋ និងបទដ្ឋានបច្ចេកទេស។ វិធីសាស្ត្រនេះអនុវត្តចំពោះ តំបន់មានដែលសេវាកម្មស្រាប់ និងក្នុងតំបន់ដែលនឹងទទួលនូវជំនួយឧបត្ថម្ភនានា។

២- វិធីសាស្ត្រដោះស្រាយតាមតម្រូវការៈ ផ្ទេរការយកចិត្តទុកដាក់ពីអ្នកផ្គត់ផ្គង់ទៅអ្នក ប្រើប្រាស់ ឯបទដ្ឋានបច្ចេកទេសនានាផ្អែកលើអ្នកប្រើប្រាស់ចង់បានដែលមានលទ្ធភាព និងយល់ព្រមបង់ថ្លៃ អនុវត្តចំពោះតំបន់ដែលពុំទាន់មានសេវាផ្គត់ផ្គង់ និងតំបន់ដែល វិនិយោគដោយឯកជន។

# ២. ការចូលរួមពីផ្នែកឯកជន

១- កិច្ចសន្យាសាងសង់-ដំណើរការ-ផ្ទេរ ( Build Operation Transfer )

២- កិច្ចសន្យាសាងសង់-ដំណើរការ-គ្រប់គ្រង ( Build Operation Own )

៣- សិក្សាប្លង់-សាងសង់-ដំណើរការ ( Output Based Aid )

៤- សិក្សាប្លង់-សាងសង់-ជួលដំណើរការ ( Design Build Lease )

# ៣. ការកំណត់ថ្លៃទឹក

" តារាងតម្លៃ ត្រូវតែអាចទូទាត់សោហ៊ុយចំណាយបានទាំងស្រុង និងធានាប្រសិទ្ធភាពនៃការប្រមូលប្រាក់ "

១- តារាងតម្លៃ ត្រូវផ្សព្វផ្សាយជាមុន ដើម្បីអោយអតិថិជនអាចសម្រួលបរិមាណប្រើប្រាស់ ដើម្បីមានលទ្ធភាពទូទាត់តម្លៃតាមវិក្កយប័ត្រ។

២- ត្រូវមានរូបមន្ត និងនិតិវិធីច្បាស់លាស់សំរាប់ពិនិត្យ និងកែសំរួលតម្លៃឡើងវិញជារៀងរាល់៥ឆ្នាំម្តង

៣- ត្រូវបញ្ចប់នូវទម្លាប់ការប្រើប្រាស់ទឹកមិនបង់ប្រាក់។

៤- ត្រូវដាក់ទោសពិន័យចំពោះការបង់ប្រាក់យឺតយ៉ាវ ដោយកំណត់អោយច្បាស់ និងមានតម្លាភាព។

# ៤. ការការពារជនក្រីក្រ និងការឧបត្ថម្ភធន

″ កំណត់អនុវត្តគោលនយោបាយឧបស្ថម្ភធនដោយប្រយោលលើការកំណត់តារាងតំលៃ (Tariff subsidize) ដើម្បីអោយជនក្រីក្រទទួលបាននូវទឹកស្អាតសម្រាប់ប្រើប្រាស់ ទន្ទឹមនឹងនេះត្រូវយកចិត្តទុកដាក់ក្នុងការ តភ្ជាប់បណ្តាញសម្រាប់ជនក្រីក្រ តាមរយៈវិធីឧបត្ថម្ភធនដោយផ្ទាល់ ឬវិធីផ្តល់ឥណទាន ឬសាងសង់ចំណុចចែកចាយទឹករួមសំរាប់សហគមន៍ក្រីក្រ ...″

# ៤. ការការពារជនក្រីក្រ និងការឧបត្ថម្ភធន (ត)

១- ត្រូវមានតារាងតម្លៃ ដែលមានបែងចែកជាប្រភេទ ដោយយកឯកតាការប្រើប្រាស់ជាមូលដ្ឋាន ពោលគឺគិតតម្លៃតិចជាងតម្លៃមធ្យមចំពោះអ្នកប្រើប្រាស់ទឹកតិច និងគិតតម្លៃលើសពីតម្លៃមធ្យម ចំពោះអ្នកប្រើប្រាស់ទឹកច្រើន។

២- បង្កលក្ខណៈងាយស្រួលដល់អ្នកក្រីក្រ ដែលពុំមានលទ្ធភាពបង់ថ្លៃតភ្ជាប់បណ្តាញ តាមរយៈ វិធីឧបត្ថម្ភធនដោយផ្ទាល់ ឬវិធីផ្តល់ឥណទាន ឬបង់រំលោះ ...។

៣- ករណីប្រជាជនក្រីក្ររស់នៅប្រមូលផ្តុំជាសហគមន៍ ដោយតតម្លើងចំណុចចែកចាយទឹករួម ហើយប្រជាពលរដ្ឋក្នុងសហគមន៍ ជាអ្នកទទួលបន្ទុកចំណាយក្នុងការតភ្ជាប់ និងបង់ប្រាក់ថ្លៃ ប្រើប្រាស់ទឹកតាមវិក្កយប័ត្រ។

# ៥. ស្វ័យភាពនៃអង្គភាពសេវាសាធារណៈ

" អនុវត្តន៍នូវយន្តការវិមជ្ឈការ និងដាក់ចេញនូវផែនការស្វ័យភិបាល
សេដ្ឋកិច្ចដល់អង្គភាពសេវាសាធារណៈ និងឈានទៅបង្កើតជា
សហគ្រាសសាធារណៈ ទៅតាមស្ថានភាពជាក់ស្តែង "

# ៥. ស្វ័យភាពនៃអង្គភាពសេវាសាធារណៈ (ត)

១- ត្រូវអនុវត្តវិមជ្ឈការ ដោយបែងចែកនិងកំណត់តួនាទី ការទទួលខុសត្រូវលើការគ្រប់គ្រង ហិរញ្ញវត្ថុ និងការគ្រប់គ្រងអោយបានច្បាស់លាស់រវាង ក្រសួង ឧ រ ថ និងអាជ្ញាធរដែនដី។

២- រៀបចំផែនការ ដាក់អោយរដ្ឋាករទឹកខេត្ត-ក្រុង អនុវត្តនូវរបបស្វ័យភិបាលសេដ្ឋកិច្ច។

៣- ក្រសួងពាក់ព័ន្ធ និង អាជ្ញាធរដែនដី ត្រូវធានាគ្រប់បែបយ៉ាងតាមផ្លូវច្បាប់ ដើម្បីអោយរដ្ឋាករទឹកស្វយ័ត អាចដំណើរការដោយឯករាជ្យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

# ៦. បញ្ញត្តករទឹកស្អាត

″ បង្កើតបញ្ញត្តិករទឹកស្អាតឯករាជ្យ សំរាប់ផ្នែកផ្គត់ផ្គង់ទឹកស្អាតនៅទូទាំង-ប្រទេស ដើម្បីទាក់ទាញនូវទំនុកចិត្តពីអង្គភាពសាធារណៈ និងផ្នែកឯកជន ហើយដើរតួនាទីជាយន្តការត្រួតពិនិត្យ ដ៏មានទំនុកចិត្ត មានសមត្ថភាព អព្យាក្រិត្យ និងការពារយ៉ាងត្រឹមត្រូវ នូវផលប្រយោជន៍របស់អ្នកពាក់ព័ន្ធ-ទាំងអស់ ″

# ៦. បញ្ញត្តករទឹកស្អាត (ត)

១- ឯករាជ្យក្នុងការអនុវត្តការត្រួតពិនិត្យ ចំពោះអង្គភាពសាធារណៈ និងប្រតិបត្តិករឯកជន។

បញ្ញត្តិករទឹកស្អាតមានសមាជិកពី៥ទៅ៧រូប តែងតាំងដោយព្រះរាជក្រឹត សំរាប់អាណត្តិ៥ឆ្នាំ។

២- ត្រូវមានក្រុមហ៊ុនជំនាញវិជ្ជាជីវៈអន្តរជាតិ ដើម្បីកសាងសមត្ថភាពដល់មន្ត្រីបញ្ញត្តិករ។

៣- តួនាទីបញ្ញត្តិករទឹកស្អាតៈ

ក- ពង្រីកសេវាកម្មទឹកស្អាតទូទាំងប្រទេស ៖

- ការពារផលប្រយោជន៍របស់អតិថិជន
- ការពារវិនិយោគិន

AGENDA FOR CHANGE | water.org | Australian Aid | THE AUSTRALIAN WATER PARTNERSHIP | PPIAF Enabling Infrastructure Investment | CAP RED | WaterAid

# ៦. បញ្ញត្តករទឹកស្អាត (ត)

- ជំរុញប្រសិទ្ធភាពការផ្តល់សេវា តាមរយៈការប្រកួតប្រជែង
- ដោះស្រាយរាល់វិវាទ របស់អង្គភាពផ្គត់ផ្គង់ទឹកស្អាត និងឯកជន
- ផ្តល់អាជ្ញាប័ណ្ណដល់អង្គភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន
- អ្នកទទួលអាជ្ញាប័ណ្ណត្រូវមានសមត្ថភាព និងធានាកិច្ចដំណើរការផ្នែកហិរញ្ញវត្ថុ
- ពិនិត្យវាយតម្លៃហិរញ្ញវត្ថុ និងការគ្រប់គ្រងរបស់អ្នកផ្គត់ផ្គង់សេវា
- កំណត់ព្រំប្រទល់តំបន់អាជីវកម្ម និងសេវាដែលត្រូវផ្គត់ផ្គង់
- ត្រួតពិនិត្យការប្រតិបត្តិរបស់អាជ្ញាប័ណ្ណ និងមានសិទ្ធព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណ

# ៦. បញ្ញត្តករទឹកស្អាត (ត)

គ- រៀបចំកំណត់តារាងតម្លៃទឹក ត្រួតពិនិត្យ និងកែប្រែលើតារាងតម្លៃ។

ឃ- កំណត់ស្តង់ដាគុណភាពទឹក និងត្រួតពិនិត្យការអនុវត្តរបស់អង្គភាព-ផ្គត់ផ្គង់ទឹកសាធារណៈ និងឯកជន។

# II. គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត-ក្រុង និងទីប្រជុំជន

១. គោលបំណង

២. គោលដៅ

៣. វិសាលភាព

៤. យុទ្ធសាស្ត្រ

# II.គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត–ក្រុង និងទីប្រជុំជន (ត)

១. គោលបំណង៖ ដើម្បីគាំទ្រការអនុវត្តន៍គោលនយោបាយ គោលដៅ និងយុត្តិសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីធានា គុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ ព្រមទាំងចូលរួមជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

# II.គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត–ក្រុង និងទីប្រជុំជន (ត)

២. គោលដៅ៖ អភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត អោយមានប្រសិទ្ធភាព សមធម៌ និងមាននិរន្តរភាព ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងគាំទ្រការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ។

# II.គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត–ក្រុង និងទីប្រជុំជន (ត)

៣. វិសាលភាព៖ អនុវត្តចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលស្ថិតក្រោមបរិបទការធ្វើអាជីវកម្ម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

# II.គម្រោងធ្វើបច្ចុប្បន្នភាព គោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ខេត្ត–ក្រុង និងទីប្រជុំជន (ត)

៤. យុទ្ធសាស្ត្រ៖

– ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធការងាររវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋអំណាចមូលដ្ឋាន

– ជម្រុញការអនុវត្តន៍ គោលនយោបាយ គោលដៅ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

– ជម្រុញប្រសិទ្ធភាព និងការចូលរួមអភិវឌ្ឍន៍ពីវិស័យសាធារណៈ ឯកជនជាតិ និងអន្តរជាតិ

– ....

# សូមអរគុណ !